## សំណួរនិងចម្លើយ

**ស: ធ្វើម្តេចខ្ញុំនឹងដឹងថាកូនខ្ញុំអាចនឹងត្រូវដាក់ឲ្យរៀនត្រួតថ្នាក់?**

**ច:** មាតាបិតាគប្បីត្រូវអានរបាយការណ៏សមិទ្ធិកម្មរបស់កូនគាត់ដើម្បីតាមដានមើលការលូតលាស់។ មាតាបិតានឹងត្រូវបានផ្តល់ដំណឹងជាទៀងទាត់នៅក្នុងពេលជួបប្រជុំរវៀងមាតាបិតានិងគ្រូបង្រៀនតាមពេលកកំណត់ឬនៅក្នុងពេលប្រជុំពិសេស បើចាំបាច់។ សំបុត្រនឹងត្រូវផ្ញើរទៅផ្ទះជូនដំណឹងមាតាបិតាថាកូនគាត់ពុំាន់មានចំណេះស្មើកំរិតថ្នាក់ទេហើយអាចនឹងត្រូវដាក់ឲ្យរៀនត្រួតថ្នាក់។ សិស្សដែលអាចនឹងត្រូវដាក់ឲ្យរៀនត្រួតថ្នាក់នឹងត្រូវអាចផ្តល់ឲ្យនូវការបង្ហាត់បង្រៀនបន្ថែមនៅសាលារៀន។

**ស: តើអន្តរាគមអ្វីខ្លះដែលនឹងមានផ្តល់ឲ្យសិស្ស?**

**ច:** នៅពេលសិស្សរៀនមិនទាន់មានចំណេះស្មើនឹងកំរិតថ្នាក់ យោងទៅតាមការស្ទង់ប្រមាណខ្នាតគំរូផ្នែកអាននិងមេលេខគណិតសាស្ត្រ សិស្សនោះអាចនឹងត្រូវផ្តល់ឲ្យនូវការបង្ហាត់បង្រៀនបន្ថែម ដូចជា ការបង្ហាត់បង្រៀននៅក្នុងក្រុមសិស្សដែលមានចំនួនតូច ការបង្ហាត់ពន្យល់នៅពេលក្រោយម៉ោងសាលា ឲ្យមករៀននៅក្នុងវិស្សមកាល ឬដាក់ឲ្យរៀនក្នុងថ្នាក់រៀនអាននិងសរសេរ។ សាលារៀនទាំងអស់នឹងផ្តល់ឱកាសជាអតិបរិមាណដល់សិស្សដើម្បីឲ្យពួកគេមានជោគជ័យក្នុងការសិក្សា។ មាតាបិតានឹងត្រូវរំពឹងថានឹងផ្តល់ការគាំទ្រនៅផ្ទះហើយនឹងត្រូវផ្តល់ការអប់រំមាតាបិតាដើម្បីរៀនអំពីរបៀបគាំទ្រកូននៅផ្ទះ។

**ស: តើខ្ញុំអាចជួយកូនខ្ញុំនៅផ្ទះតាមរបៀបណា?**

**ច:** មាតាបិតាគប្បីទាក់ទងគ្រូបង្រៀនរបស់កូនគាត់ដើម្បីរកជំនួយ។ សម្ភារៈនិងសកម្មភាពផ្សេងៗអាចផ្តល់ឲ្យសំរាប់អានសរសេរ និងហាត់ធ្វើគណិតនៅផ្ទះ។ សាលារៀនតែងតែមានផ្តល់ការអប់រំដល់មាតាបិតាហើយមាតាបិតាអាចចូលទៅក្នុងវែបសាយរបស់យើងនៅ www.lbschools.net. (រួចចុចលើ "Parent University" បន្ទាប់មកចុចលើ "Home Activities and Support")

## សំណួរនិងចម្លើយ

**ស: តើមានកម្មវិធីអ្វីទៀតក្រៅពីកម្មវិធីរបស់ក្រសួងអប់រំដែលខ្ញុំអាចបញ្ជូនកូនខ្ញុំទៅ?**

**ច:** មាតាបិតាអាចជ្រើសរើសចុះឈ្មោះកូនគាត់ឲ្យរៀនក្នុងកម្មវិធីឯកជននៅរដូវក្តៅឬនៅមណ្ឌលបង្ហាត់ពន្យល់បន្ថែម។ សិស្សនឹងទទួលការស្ទង់ប្រមាណមើលចំណេះនៅសាលារៀនហើយអាចយករបាយការណ៏សមិទ្ធិកម្មឬការស្ទង់ប្រមាណក្នុងថ្នាក់រៀនទៅឲ្យមណ្ឌលបង្ហាត់បង្រៀនបន្ថែមដើម្បីជួយគិតរកមើលសេចក្តីចាំបាច់របស់សិស្ស។

**ស: ប្រសិនបើសិស្សធ្វើមិនជាប់តែសផ្នែកគិតលេខស្របតាមលក្ខណៈវិនិច្ឆ័យនៃការឲ្យឡើងថ្នាក់ តើសិស្សនោះនឹងត្រូវដាក់ឲ្យរៀនត្រួតថ្នាក់ដែរឬទេ?**

**ច:** ប្រាកដណាស់។ សិស្សពីថ្នាក់ទី១ដល់ទី៥នឹងត្រូវផ្តល់ឱកាសឲ្យជាអតិបរិមាណដើម្បីឲ្យមានជោគជ័យលើការធ្វើតែសគិតលេខនៅក្រោមស្ថានភាពតែសជាស្តង់ដា។ ប្រសិនបើសិស្សរៀនក្នុងកម្មវិធីអប់រំពិសេស ការសម្របសម្រួលអាចនឹងមានផ្តល់ឲ្យ ដូចមានចែងនៅក្នុងផែនការណ៏សិក្សាផ្ទាល់ខ្លួនរបស់សិស្សក្នុងកម្មវិធីអប់រំពិសេស IEP។

**ស: ក្នុងនាមជាមាតាបិតា តើខ្ញុំមានសិទ្ធិបដិសេធដល់ការដាក់ឲ្យកូនខ្ញុំរៀនត្រួតថ្នាក់ដែរឬទេ?**

**ច:** នៅពេលបានទទួលអនុសាសន៏នៃការដាក់ឲ្យរៀនត្រួតថ្នាក់ក្រុមទទួលបន្ទុកផ្នែកឲ្យសិស្សឡើងថ្នាក់នៅសាលារៀននឹងជួបប្រជុំដើម្បីពិនិត្យមើលសារឡើងវិញនូវលក្ខណៈវិនិច្ឆ័យ ប្រវត្តិ-ការណ៏សិក្សា ទិន្នន័យជាមួយមាតាបិតា។ ក្រុមរួមទាំងមាតាបិតានឹងធ្វើការសម្រេចជាចុងក្រោយ។ ប្រសិនបើមាតាបិតាមិនយល់ស្របជាមួយអនុសាសន៏នៃការដាក់កូនគាត់ឲ្យរៀនត្រួតថ្នាក់ទេ មាតាបិតាអាចដាក់ពាក្យឧទ្ធរណ៏ដល់ការសំរេចរបស់សាលារៀន។

ដើម្បីឲ្យបានដឹងថែមទៀតអំពីបទបញ្ញានៃការឲ្យសិស្សឡើងថ្នាក់និងការដាក់ឲ្យរៀនត្រួតថ្នាក់ សូមចូលទៅវែបសាយ www.lbschools.net រួចចុចលើ "Retention" ពីបញ្ជីលេខរៀងអក្សរ។

long beach unified school district

# បទបញ្ញាស្តីពីការឡើងថ្នាក់និងរៀនត្រួតថ្នាក់សម្រាប់សាលាបឋមសិក្សា



## ប្រវត្តិ

កាលពីឆ្នាំ១៩៩៦ក្រុមប្រឹក្សាភិបាលការអប់រំបានធ្វើការយល់ព្រមដល់វិធានការណ៏កំណែឲ្យប្រសើរឡើងការអប់រំលើកទី១ដែលទាក់ទិននឹងការឡើងថ្នាក់និងការរៀនត្រួតថ្នាក់។ តាំងពីពេលនោះមកបទបញ្ញាមួយចំនួនសំរាប់ថ្នាក់ទី១ទី៥បានក្លាយជាចំណែកមួយនៃផែនការណ៏ទូទៅរបស់ក្រសួងអប់រំដើម្បីធ្វើឲ្យប្រសើរឡើងដល់សមិទ្ធិកម្មរបស់សិស្ស ដោយតំរូវសិស្សរៀនឲ្យមានចំណេះស្មើលក្ខណះវិនិច្ឆ័យផ្នែកអាននិងគណិតសាស្រ្ត។

## គោលបំណង

ជំហានមាំមួនមួយឆ្ពោះទៅការបញ្ចប់នូវការចេះតែឲ្យសិស្សឡើងថ្នាក់បានចាប់ផ្តើមឡើងនៅពេលក្រសួងអប់រំឡុងប៊ីចបានធ្វើការយល់ព្រមទៅលើបទបញ្ញាលើកទីដំបូងស្តីពីការឡើងថ្នាក់និងរៀនត្រួតថ្នាក់។ បទបញ្ញាស្តីពីការឡើងថ្នាក់និងរៀនត្រួតថ្នាក់បញ្ជាក់ថាសិស្សទាំងអស់បានទទួលជំនាញសំខាន់ៗហើយឈានដល់ស្តង់ដាខ្ពស់ក្នុងសមិទ្ធិកម្មនៃការសិក្សា។ នៅគ្រប់កំរិតថ្នាក់ពីថ្នាក់ទី១ដល់ទី៥ លក្ខណះវិនិច្ឆ័យនៃការឡើងថ្នាក់មួយត្រូវបានបង្កើតឡើងដែលតំរូវឲ្យសិស្សឈានដល់កំរិតអតិបរិមាណនៃសមិទ្ធិកម្មមុននឹងឡើងទៅកំរិតបន្ទាប់ទៀត។

## សេចក្តីរំពឹង

ក្រុមប្រឹក្សាភិបាលរំពឹងថាសិស្សមានការលូតលាស់ទៅតាមកំរិតថ្នាក់នីមួយៗនៅក្នុងអំឡុងរយៈពេលមួយឆ្នាំសិក្សា។ ដើម្បីធ្វើឲ្យបានសម្រេចយ៉ាងនេះ ការបង្ហាត់បង្រៀនគប្បីត្រូវតែសម្របទៅតាមរបៀបផ្សេងៗដែលសិស្សរៀនហើយមានរួមទាំងយុទ្ធសាស្រ្តផ្សេងៗដើម្បីបំពេញដល់ភាពខ្វះខាតនៃចំណេះវិជ្ជា នៅពេលណាចាំបាច់។

long beach unified school district
1515 Hughes Way
Long Beach, CA 90810
www.lbschools.net

# បទបញ្ញាស្តីពីការឡើងថ្នាក់និងរៀនត្រួតថ្នាក់ សម្រាប់សាលាបឋមសិក្សា

### ការរៀនត្រួតថ្នាក់នៅថ្នាក់ទី១

សិស្សថ្នាក់ទី១ត្រូវចេះអានកំរិតពាក់កណ្តាលថ្នាក់ទី១នូវខ្នាតគំរូទាំងការនិពន្ធប្រឌិតនិងទាំងការនិពន្ធពិតៗហើយត្រូវបានទទួលពិន្ទុកំរិតលេខ៣នៅក្នុងការធ្វើលេខបូកដែលមានចំនួនដល់១០ និងការធ្វើលេខដកដែលមានសំណល់ចំនួន១០នៅចុងឆ្នាំសិក្សា។បើកូនលោកអ្នកពុំមានចំណេះស្របតាមសេចក្តីរំពឹងនេះទេ កូនលោកអ្នកនឹងត្រូវផ្តល់អនុសាសន៏ដើម្បីឲ្យរៀនត្រួតថ្នាក់។

### ការរៀនត្រួតថ្នាក់នៅថ្នាក់ទី២

សិស្សថ្នាក់ទី១ត្រូវចេះអានកំរិតចុងថ្នាក់ទី១នូវខ្នាតគំរូទាំងការនិពន្ធប្រឌិតនិងទាំងការនិពន្ធពិតៗហើយត្រូវបានទទួលពិន្ទុកំរិតលេខ៣នៅក្នុងការធ្វើលេខបូកនិងលេខដក។ បើកូនលោកអ្នកពុំមានចំណេះស្របតាមសេចក្តីរំពឹងនេះទេ កូនលោកអ្នកនឹងត្រូវផ្តល់អនុសាសន៏ដើម្បីឲ្យរៀនត្រួតថ្នាក់។

### ការរៀនត្រួតថ្នាក់នៅថ្នាក់ទី៣

សិស្សថ្នាក់ទី១ត្រូវចេះអានកំរិតចុងថ្នាក់ទី២នូវខ្នាតគំរូទាំងការនិពន្ធប្រឌិតនិងទាំងការនិពន្ធពិតៗហើយត្រូវបានទទួលពិន្ទុកំរិតលេខ៣នៅក្នុងការធ្វើលេខបូកនិងលេខដកនិងកំរិតលេខ២ក្នុងការធ្វើលេខគុណនិងលេខចែក។ បើកូនលោកអ្នកពុំមានចំណេះស្របតាមសេចក្តីរំពឹងនេះទេ កូនលោកអ្នកនឹងត្រូវផ្តល់អនុសាសន៏ឲ្យរៀនត្រួតថ្នាក់។

### ការរៀនត្រួតថ្នាក់នៅថ្នាក់ទី៤

សិស្សថ្នាក់ទី១ត្រូវចេះអានកំរិតចុងថ្នាក់ទី៣នូវខ្នាតគំរូទាំងការនិពន្ធប្រឌិតនិងទាំងការនិពន្ធពិតៗហើយត្រូវបានទទួលពិន្ទុកំរិតលេខ៣នៅក្នុងការធ្វើលេខបូក លេខដក លេខគុណនិងលេខចែកនៅចុងឆ្នាំសិក្សា។ បើកូនលោកអ្នកពុំមានចំណេះស្របតាមសេចក្តីរំពឹងនេះទេ កូនលោកអ្នកនឹងត្រូវផ្តល់អនុសាសន៏ឲ្យរៀនត្រួតថ្នាក់។

### ការរៀនត្រួតថ្នាក់នៅថ្នាក់ទី៥

សិស្សថ្នាក់ទី១ត្រូវចេះអានកំរិតចុងថ្នាក់ទី៤នូវខ្នាតគំរូទាំងការនិពន្ធប្រឌិតនិងទាំងការនិពន្ធពិតៗហើយត្រូវបានទទួលពិន្ទុកំរិតលេខ៣នៅក្នុងការធ្វើលេខបូក លេខដក លេខគុណនិងលេខចែកនៅចុងឆ្នាំសិក្សា។ បើកូនលោកអ្នកពុំមានចំណេះស្របតាមសេចក្តីរំពឹងនេះទេ កូនលោកអ្នកនឹងត្រូវផ្តល់អនុសាសន៏ឲ្យរៀនត្រួតថ្នាក់។

## នីតិវិធីនៃការឡើងថ្នាក់ និងការរៀនត្រួតថ្នាក់

**ការធ្វើទំនាក់ទំនងនិងការជូនដំណឹង**
ការប្រជុំគ្រូនិងមាតាបិតានៅសរទរដូវនិងនិទាឃរដូវ។ ការជូនដំណឹងនិទាឃរដូវ។

**អន្តរាគម**
ការគាំទ្រក្នុងថ្នាក់
ការពង្រឹងនៅផ្ទះ

**ក្រុមស្តង់ដានៃការឡើងថ្នាក់ជួបប្រជុំគ្នា**
មានៈ គ្រូ អ្នកឲ្យឱវាទ អភិបាលសាលា និងមាតាបិតា

**អនុសាសន៏ដើម្បីដាក់ឲ្យសិស្សរៀនត្រួតថ្នាក់**
ត្រូវដាក់ពាក្យឧទ្ធរណ៏បើមាតាបិតាជំទាស់

**ការពិនិត្យមើលសារឡើងវិញនិងការសម្រេចចិត្តចុងក្រោយ**